## របាយការណ៍
## ស្តីពី
# ការតាមដានវឌ្ឍនភាពនៃប្រព័ន្ធគាំពារសង្គមកម្ពុជា

គាំពារ សង្គម កម្ពុជា
SOCIAL PROTECTION IN CAMBODIA

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម
ខែមីនា ឆ្នាំ២០២៤

# របាយការណ៍
# ស្ដីពី
# ការតាមដាន
# វឌ្ឍនភាពនៃប្រព័ន្ធ
# គាំពារសង្គមកម្ពុជា

# មាតិកា


**បញ្ជីរូបភាព** .......... I

**បញ្ជីតារាង** .......... II

**អក្សរកាត់** .......... III

**អារម្ភកថា** .......... IV

**សេចក្តីសង្ខេប** .......... VI

**១. សេចក្តីផ្តើម** .......... ១

**២. ការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គម** .......... ៤

**៣. ការគ្រប់ដណ្តប់នៃប្រព័ន្ធគាំពារសង្គម** .......... ៩

៣.១. ផ្នែកថែទាំសុខភាព .......... ១០

៣.១.១. វឌ្ឍនភាពនៃការអនុវត្តមូលនិធិសមធម៌សុខាភិបាល សម្រាប់គ្រួសារក្រីក្រ .......... ១០

៣.១.២. វឌ្ឍនភាពនៃការអនុវត្តមូលនិធិសមធម៌សុខាភិបាល សម្រាប់ក្រុមប្រជាជនដទៃ .......... ១២

៣.១.៣. វឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិត .......... ១៣

៣.២. ផ្នែកហានិភ័យការងារ .......... ១៦

៣.២.១. វឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់កម្មករនិយោជិត .......... ១៧

៣.៣. ការឆ្លើយតបនឹងគ្រោះអាសន្ន .......... ១៨

៣.៣.១. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ .......... ២០

៣.៣.២. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ .......... ២២

៣.៣.៣. ការបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករនិយោជិត .......... ២៤

៣.៣.៤. ប្រព័ន្ធស្បៀងបម្រុង .......... ២៥

**៤. សេចក្តីសន្និដ្ឋាន** .......... ២៦

# បញ្ជីរូបភាព


រូបភាពទី១ និន្នាការនៃការវិនិយោគ (ចំណាយ) ក្នុងប្រព័ន្ធគាំពារសង្គម ..... ៥
រូបភាពទី២ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ..... ៥
រូបភាពទី៣ ការវិនិយោគក្នុងប្រព័ន្ធជំនួយសង្គម និងសន្តិសុខសង្គម (%ផ.ស.ស) ..... ៦
រូបភាពទី៤ ការវិនិយោគក្នុងប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម ..... ៦
រូបភាពទី៥ ការវិនិយោគតាមកម្មវិធីក្នុងប្រព័ន្ធជំនួយសង្គម ឆ្នាំ២០២២ (%) ..... ៨
រូបភាពទី៦ ការវិនិយោគតាមរបប/មូលនិធិ ក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ២០២២ (%) ..... ៨
រូបភាពទី៧ អត្រាគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម (% ចំនួនប្រជាជនសរុប) ..... ៩
រូបភាពទី៨ ចំនួនអត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារក្រីក្រ ..... ១១
រូបភាពទី៩ អត្រានៃការប្រើប្រាស់របស់អត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារក្រីក្រ ..... ១១
រូបភាពទី១០ ចំនួនអត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ ..... ១២
រូបភាពទី១១ វិសមភាពភេទនៃអត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ ..... ១២
រូបភាពទី១២ អត្រានៃការប្រើប្រាស់របស់អត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ ..... ១៣
រូបភាពទី១៣ ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ..... ១៤
រូបភាពទី១៤ បច្ចុប្បន្នភាពនៃចំនួនសហគ្រាសនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ..... ១៤
រូបភាពទី១៥ ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ..... ១៥
រូបភាពទី១៦ ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ឆ្នាំ២០២២ ..... ១៥
រូបភាពទី១៧ អត្រានៃការប្រើប្រាស់របស់អត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ..... ១៥
រូបភាពទី១៨ ថវិកាដែលបានផ្ទេរក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ..... ១៦
រូបភាពទី១៩ ថវិកាដែលបានផ្ទេរក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតឆ្នាំ២០២២ ..... ១៦
រូបភាពទី២០ ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ..... ១៧
រូបភាពទី២១ បច្ចុប្បន្នភាពនៃចំនួនសហគ្រាសនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ..... ១៧
រូបភាពទី២២ ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ..... ១៨
រូបភាពទី២៣ ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ឆ្នាំ២០២២ ..... ១៨
រូបភាពទី២៤ ថវិកាបានផ្ទេរក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ..... ១៩
រូបភាពទី២៥ ថវិកាបានផ្ទេរក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ..... ១៩
រូបភាពទី២៦ ថវិកាចំណាយប្រចាំឆ្នាំ ពីឆមាសទី២ ឆ្នាំ២០២០ ដល់ដំណាច់ឆ្នាំ២០២៣ ..... ២១
រូបភាពទី២៧ តាវកាលិក, ចំនួនគ្រួសារ, និងអត្ថគាហក ..... ២២

# បញ្ជីតារាង


**តារាងទី១** កម្មវិធីជំនួយសង្គម, របបសន្តិសុខសង្គម, និងសមាសធាតុកម្មវិធីក្នុងយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ..... ២

**តារាងទី២** កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា ..... ២៣

**តារាងទី៣** ចំនួនអត្ថគាហក នៃកម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ និង កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិត ដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់ ..... ២៤

**តារាងទី៤** ចំនួនគ្រួសារ ដែលទទួលបានការឧបត្ថម្ភ ពីប្រព័ន្ធស្បៀងបម្រុង ..... ២៥

**តារាងទី៥** តារាងសង្ខេបនៃចំនួនអត្ថគាហក កម្រិតនៃការគ្របដណ្តប់ អត្រានៃការប្រើប្រាស់ និងថវិកាបានផ្ទេរ ក្នុងរបប និងកម្មវិធីគាំពារសង្គមនីមួយៗ ..... ២៧

# អក្សរកាត់

| | |
|---|---|
| ក.ស.ហ.វ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ក.ស.ខ | ក្រសួងសុខាភិបាល |
| ក.ក.ប | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក.ស.អ.យ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ក.អ.យ.ក | ក្រសួងអប់រំ យុវជន និងកីឡា |
| ប.ស.ស | បេឡាជាតិសន្តិសុខសង្គម |
| ប.ជ.ស | បេឡាជាតិមន្ត្រីរាជការសាធារណៈ |
| ប.ជ.អ | បេឡាជាតិអតីតយុទ្ធជន |
| ម.ជ.ព | មូលនិធិជាតិជនពិការ |
| ម.ធ.ស | មូលនិធិសមធម៌សុខាភិបាល |
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប |
| ទ.ជ.ប | ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ |

# អារម្ភកថា

ជាមួយនឹងគោលដៅក្នុងការកសាងប្រព័ន្ធគាំពារសង្គមមួយដែលមានភាពរឹងមាំ បត់បែន និងប្រកបដោយបរិយាបន្ន, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដែលជាមគ្គុទ្ទេសក៍បង្ហាញផ្លូវរយៈពេលវែងសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។ ឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ, កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០, យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ( Monitoring and Evaluation Mechanism ) ដែលជាយន្តការរួមថ្នាក់ជាតិ និងមានលក្ខណៈជាប្រព័ន្ធត្រូវបានដាក់ចេញឱ្យអនុវត្តដោយក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អ, តម្លាភាព, គណនេយ្យភាព ក៏ដូចជាបង្កើនប្រសិទ្ធភាពនៃការអនុវត្ត។

យន្តការនេះ បានកំណត់នូវវិធាន, នីតិវិធី, និងសូចនាករសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីជំនួយសង្គម, របបសន្តិសុខសង្គម ព្រមទាំងវឌ្ឍនភាពនៃការកសាងប្រព័ន្ធគាំពារសង្គមកម្ពុជា ដែលមានក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រតិបត្តិករគាំពារសង្គមចំនួន១២ មានកាតព្វកិច្ចផ្តល់ទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តជាអង្គភាពរាយការណ៍ ដែលក្នុងនោះរួមមាន៖ក្រសួងសុខាភិបាល, ក្រសួងផែនការ, ក្រសួងអប់រំ យុវជន និងកីឡា, អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និយ័តករសន្តិសុខសង្គម, បេឡាជាតិសន្តិសុខសង្គម, មូលនិធិជាតិជំនួយសង្គម, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, វិទ្យាស្ថានជាតិសុខភាពសាធារណៈ, វិទ្យាស្ថានជាតិស្ថិតិ, ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ, និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

ទន្ទឹមនេះ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ( SPME database system ) ត្រូវបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីចុងឆ្នាំ២០២១ ដើម្បីសម្រួល, បង្កើនប្រសិទ្ធភាពនៃការរាយការណ៍ និងគ្រប់គ្រងទិន្នន័យក្នុងក្របខណ្ឌការងារប្រតិតុល្យការសម្រាប់គ្រប់អង្គភាពរាយការណ៍ទាំងអស់។ តាមរយៈទិន្នន័យដែលគ្រប់អង្គភាពរាយការណ៍បានបញ្ចូលក្នុងប្រព័ន្ធ SPME, ក្រុមប្រឹក្សាជាតិគាំពារសង្គមបានរៀបចំចងក្រងរបាយការណ៍តាមដានវឌ្ឍនភាពនៃប្រព័ន្ធគាំពារសង្គមនេះឡើង ដោយបានឆ្លុះបញ្ចាំងពីនិន្នាការនៃការវិនិយោគ ( ចំណាយ ) ព្រមទាំងការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម។

ជាលទ្ធផលក្នុងរយៈពេលជាង ៥ឆ្នាំកន្លងមកនេះ, ការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គមបានកើនឡើងពីប្រមាណ ១% នៃផលិតផលសរុបក្នុងស្រុក ( ផ.ស.ស ) ក្នុងឆ្នាំ២០១៨ ដល់ប្រមាណ ៣,១% នៃ ផ.ស.ស ក្នុងឆ្នាំ២០២២ ជាមួយនឹងអត្រាគ្របដណ្តប់បានកើនឡើងពី ២៦,៥% ក្នុងឆ្នាំ២០១៨ ដល់ប្រមាណ ៤២% នៃចំនួនប្រជាជនសរុបក្នុងឆ្នាំ២០២២ ដែលនេះជាលទ្ធផលមួយឆ្លុះបញ្ចាំងពីឆន្ទៈ, ការយកចិត្តទុកដាក់, និងកិច្ចខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការកសាង និងពង្រឹងប្រព័ន្ធគាំពារសង្គមកម្ពុជាឱ្យបានកាន់តែប្រសើរឡើងជាជំហានៗ។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម, ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំរបស់ក្រុមការងារបច្ចេកទេស និងថ្នាក់ដឹកនាំនៃបណ្តាក្រសួង-ស្ថាប័ន ក៏ដូចជាប្រតិបត្តិករគាំពារសង្គមទាំងអស់ ដែលបានសហការយ៉ាងសកម្មក្នុងការផ្តល់ព័ត៌មាន និងបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ SPME ក្រោមការសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលឈានទៅចងក្រងបាននូវរបាយការណ៍តាមដានវឌ្ឍនភាពនៃប្រព័ន្ធ

គាំពារសង្គមនេះឡើង។ វឌ្ឍនភាពនេះជាសក្ខីភាពដ៏មានសារៈសំខាន់ នៃការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលគ្រប់នីតិកាល ទាំងក្នុងអំឡុងពេលដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាអគ្គមគ្គុទេសក៍ឯក និងរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលមាន **សម្តេចអគ្គមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខដ៏វៃឆ្លាត និងប្រកបដោយថាមពល និងចក្ខុវិស័យច្បាស់លាស់ ដោយសម្តេចទាំងទ្វេតែងតែឈរលើគោលការណ៍រួមមួយគឺ "មិនបោះបង់ពលរដ្ឋណាម្នាក់" និងបានខិតខំកសាងប្រព័ន្ធគាំពារសង្គមមួយប្រកបដោយបរិយាបន្ន។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់បណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធទាំងអស់ ជាពិសេសទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) ដែលតែងតែបានផ្តល់ការគាំទ្រលើការរៀបចំកសាង និងអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមនេះ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

# សេចក្ដីសង្ខេប

យោងតាមវឌ្ឍនភាពនៃការបញ្ចូលទិន្នន័យរបស់ក្រសួង-ស្ថាប័នដែលជាអង្គភាពរាយការណ៍ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម អាចតាមដានវឌ្ឍនភាពប្រព័ន្ធគាំពារសង្គម រយៈពេល៥ឆ្នាំ ពាក់ព័ន្ធនឹងការវិនិយោគ, ការគ្របដណ្ដប់, និងលទ្ធផល នៃការអនុវត្តកម្មវិធីជំនួយសង្គម, របបសន្តិសុខសង្គម និងការឆ្លើយតបនឹងគ្រោះអាសន្នមួយចំនួន។





- កម្មវិធីឧបត្ថមសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩
- កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករនិយោជិត
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ
- ប្រព័ន្ធស្បៀងបម្រុង

**ការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គម៖** ការវិនិយោគរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្នុងប្រព័ន្ធគាំពារសង្គមមានការកើនឡើងជាខ្លាំង។ ជាក់ស្តែង ការវិនិយោគនេះបានកើនឡើងពីត្រឹម ១% នៃផ.ស.ស ឬ ៤,៥% នៃថវិកាជាតិក្នុងឆ្នាំ២០១៨ រហូតដល់ ៣,១% នៃផ.ស.ស. ឬ ១៤,០% នៃថវិកាជាតិក្នុងឆ្នាំ២០២២។

**ការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម៖** ជាលទ្ធផលនៃកិច្ចខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការកសាងប្រព័ន្ធគាំពារសង្គម អត្រានៃការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គមមានការកើនឡើងគួរឱ្យកត់សម្គាល់។ ក្នុងទិដ្ឋភាពរួម, ប្រព័ន្ធគាំពារសង្គមកម្ពុជាគ្របដណ្តប់លើប្រជាជនងាយរងគ្រោះ (ក្រុមប្រជាជនដែលមានបណ្ណសមធម៌ និងក្រុមប្រជាជនងាយរងហានិភ័យដែលនៅក្បែរបន្ទាត់ភាពក្រីក្រ) និងក្រុមប្រជាជនដែលស្ថិតក្នុងរបបសន្តិសុខសង្គម ដែលជាសមាជិកនៃរបបថែទាំសុខភាព។ អត្រានៃការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម បានកើនឡើងពីប្រមាណ ២៦,៥% នៃចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៨ ទៅប្រមាណជិត ៤២% ក្នុងឆ្នាំ២០២២។

**មូលនិធិសមធម៌សុខាភិបាល៖** មូលនិធិសមធម៌សុខាភិបាលបានគ្របដណ្តប់លើក្រុមគោលដៅចំនួន ២ គឺប្រជាជនក្រីក្រដែលមានបណ្ណសមធម៌ និងក្រុមប្រជាជនគោលដៅដទៃ (កម្មករក្រៅប្រព័ន្ធ, កីឡាករ, ក្រុមប្រឹក្សាឃុំ-សង្កាត់, មន្ត្រីភូមិ ជាដើម)។ សម្រាប់មូលនិធិសមធម៌សុខាភិបាលសម្រាប់ប្រជាជនក្រីក្រ, ចំនួនអត្ថគាហកមានការកើនឡើងពី ២លាន ៥សែននាក់ ក្នុងឆ្នាំ២០១៨ ដល់ ៣លាន ១សែននាក់ ឬ ១៨,៦% នៃប្រជាជនសរុបក្នុងឆ្នាំ២០២២ ដែលនិន្នាការនេះបានឆ្លុះបញ្ចាំងឱ្យឃើញថាវិសាលភាពនៃការគ្របដណ្តប់ដោយមូលនិធិនេះ កំពុងត្រូវបានពង្រីកកាន់តែកាន់តែធំឡើងៗ។ ក្នុងពេលជាមួយគ្នានេះ, អត្រានៃការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាល (សេវាសុខាភិបាល រួមមាន ពិគ្រោះក្រៅ សំរាកពេទ្យ និងផ្សេងៗ) ជាមធ្យមរបស់ប្រជាជនក្រីក្រនៅតាមមូលដ្ឋានសុខាភិបាលមានប្រមាណ ១ដងក្នុងមួយឆ្នាំ។ សម្រាប់មូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ, ចំនួនអត្ថគាហក មិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ទេ គឺក្នុងរង្វង់ ប្រមាណ ០,៦% នៃប្រជាជនសរុប ក្នុងឆ្នាំ២០២២។ យ៉ាងណាមិញ, អត្រានៃប្រើប្រាស់មូលនិធិសមធម៌របស់ក្រុមប្រជាជនដទៃ មានការកើនឡើងពីប្រមាណ ០,៧៧ដងក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០១៩ ដល់ប្រមាណ ០,៨១ដងក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០២២។

**របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត៖** វិសាលភាពនៃការគ្របដណ្តប់ដោយ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត មានការកើនឡើងជាបន្តបន្ទាប់ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ជាក់ស្តែង ចំនួនអត្ថគាហកនៃរបបទាំងពីរនេះបានកើនឡើងពី ១លាន ២សែននាក់ ក្នុងឆ្នាំ២០១៨ ដល់ ១លាន ៤សែននាក់ ក្នុងឆ្នាំ២០២២។ ទន្ទឹមនឹងនេះ អត្រានៃការប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រជាមធ្យមរបស់អត្ថគាហកម្នាក់ៗនៃរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិតបានកើនឡើងពី ០,៩៩ដងក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០១៨ ដល់ ១,៩៤ដងក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០២២។

**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩៖** ចាប់ពីចុងខែមិថុនា ឆ្នាំ២០២០ ដល់ ដំណាច់ឆ្នាំ២០២៣, រាជរដ្ឋាភិបាលបានផ្ទេរថវិកាសរុបប្រមាណ ៥ ០៩៩ ៨០៤,៣ លានរៀល ឬប្រមាណ ១ ២៤៣,៨៥ លានដុល្លាអាម៉េរិក ដល់គ្រួសារក្រីក្រ និងងាយរងហានិភ័យ តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩នេះ។ កម្មវិធីនេះមានវិសាលភាពនៃការគ្របដណ្ដប់ប្រជាជនសរុបប្រមាណ ១៥,៦% ក្នុងឆ្នាំ២០២០ ហើយវិសាលភាពនេះបានកើនឡើងដល់ ១៦,៥% ក្នុងឆ្នាំ២០២៣។

**កម្មវិធីបណ្ដុះបណ្ដាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករនិយោជិត៖** បន្ថែមលើការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ, រាជរដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធី និងអន្តរាគមន៍ឆ្លើយតបបន្ទាន់ដើម្បីជួយកម្មករនិយោជិត ដែលក្នុងនោះ មានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិត ដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់ ដោយបានជួយឧបត្ថម្ភកម្មករនិយោជិតប្រមាណ ៣៤ម៉ឺននាក់ (៧៩,៥% ជាស្ត្រី) និងចំណាយថវិកាអស់ប្រមាណ ៥៤,៧ ប៊ីលានរៀល។ បន្ថែមពីនេះ, កម្មវិធីបណ្ដុះបណ្ដាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ ក៏ត្រូវបានដាក់ឱ្យអនុវត្តរហូតមកដល់ពេលបច្ចុប្បន្ន ដោយបានបណ្ដុះបណ្ដាល និងជួយកម្មករនិយោជិតប្រមាណ ៣៧ម៉ឺននាក់ ក្នុងឆ្នាំ២០២០, និង ៩ម៉ឺន ៧សែននាក់ក្នុងឆ្នាំ២០២២។

**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ៖** ជាការឆ្លើយតបនឹងផលប៉ះពាល់ដែលបណ្ដាលមកពីជំងឺកូវីដ-១៩ និងសម្ពាធអតិផរណាដែលបណ្ដាលមកពីបញ្ហាសេដ្ឋកិច្ចសកល ស្របពេលដែលមានការផ្ទុះឡើងនូវជម្លោះរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន និងគ្រោះមហន្តរាយទឹកជំនន់ ក្នុងឆ្នាំ២០២២, រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ចំនួនពីរបន្ថែមទៀតគឺ កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា។ សម្រាប់កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់, រាជរដ្ឋាភិបាលបានចំណាយថវិកាសរុបអស់ប្រមាណ ៤៦ ៧៩៩,១ លានរៀល ឬប្រមាណ ១១,៤២ លានដុល្លារ ដោយបានឧបត្ថម្ភជូន ប្រជាជនប្រមាណ ៣៧២ ៨៥៩នាក់ (៣៧២ ៨៥៩ គ្រួសារ)។ សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា, រាជរដ្ឋាភិបាលបានចំណាយថវិកាសរុបអស់ប្រមាណ ១៧៥ ៦៣៨,៤៦ លានរៀល ដោយបានឧបត្ថម្ភជូនប្រជាជនសរុបចំនួន ១ ៨៣៣ ៣៤៤នាក់ (៤៩៥ ៣០៧ គ្រួសារ)។

**ប្រព័ន្ធស្បៀងបម្រុង៖** ក្នុងយន្តការឆ្លើយតបនឹងគ្រោះអាសន្ន, ប្រព័ន្ធស្បៀងបម្រុងកម្ពុជា បាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយឧបត្ថម្ភភ្លាមៗ និងជាប្រចាំដល់គ្រួសាររងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ដូចជាគ្រោះទឹកជំនន់, គ្រោះរាំងស្ងួត, ការផ្ដល់ពូជដំណាំ ដើម្បីលើកកំពស់ជីវភាពគ្រួសារ និងប្រជាកសិករនៅក្នុងប្រទេសកម្ពុជា។ ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ប្រព័ន្ធស្បៀងបម្រុងកម្ពុជា ក៏បានដើរតួនាទីយ៉ាងសំខាន់ដោយបានផ្ដល់ស្បៀងជូនគ្រួសារប្រមាណជា ៤០ម៉ឺនគ្រួសារ ក្នុងឆ្នាំ២០២១។

# ១.

# សេចក្ដីផ្ដើម

យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ត្រូវបានដាក់ឱ្យអនុវត្តដោយក្រុមប្រឹក្សាជាតិគាំពារសង្គមតាមរយៈសេចក្ដីសម្រេចលេខ០៧៥ សហវ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០។ សេចក្ដីសម្រេចនេះត្រូវបានកែសម្រួលតាមរយៈសេចក្ដីសម្រេចលេខ០៨៣ សហវ.ស.ស.រ.អ.ក.គ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣។ យន្តការនេះ បានកំណត់ពីតួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័នដែលជាប្រតិបត្តិករ(អង្គភាពរាយការណ៍) ដើម្បីផ្ដល់ទិន្នន័យសូចនាករពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី និងរបបក្នុងប្រព័ន្ធគាំពារសង្គម ដែលក្នុងនោះមានអង្គភាពរាយការណ៍ចំនួន១២ រួមមាន៖ ក្រសួងសុខាភិបាល, ក្រសួងផែនការ, ក្រសួងអប់រំ យុវជន និងកីឡា, អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និយ័តករសន្តិសុខសង្គម, បេឡាជាតិសន្តិសុខសង្គម, មូលនិធិជាតិជំនួយសង្គម, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, វិទ្យាស្ថានជាតិសុខភាពសាធារណៈ, វិទ្យាស្ថានជាតិស្ថិតិ, ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ, និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ យន្តការនេះមានសូចនាករសរុបចំនួន ៦៤ ដែលពាក់ព័ន្ធនឹងធាតុចូល (ការវិនិយោគ) (៨សូចនាករ), លទ្ធផល (១៧សូចនាករ), លទ្ធផលរយៈពេលមធ្យម (១២សូចនាករ), គោលការណ៍ (១១សូចនាករ) និងបច្ច័យ (១៦សូចនាករ) របស់ប្រព័ន្ធគាំពារសង្គម ត្រូវបានកំណត់ និងបែងចែកជូនអង្គភាពរាយការណ៍នីមួយៗ យោងតាមកម្មវិធី/របបដែលស្ថាប័ននីមួយៗអនុវត្ត។ បច្ចុប្បន្ន, មានកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមចំនួន១៦ ត្រូវបានកំណត់ក្នុងយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ដែលឆ្លើយតបទៅនឹងការវិវឌ្ឍលើទិដ្ឋភាព (សមាសធាតុ) ចំនួន៦ គឺការអភិវឌ្ឍមូលធនមនុស្ស, ប្រាក់សោធន, សុខមាលភាពរបស់ប្រជាជនងាយរងគ្រោះ, ការថែទាំសុខភាព, ហានិភ័យការងារ, និងការឆ្លើយតបនឹងគ្រោះអាសន្ន ស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥ (ដូចបានបញ្ជាក់លម្អិតក្នុងតារាងទី១)។

**តារាងទី១** កម្មវិធីជំនួយសង្គម, របបសន្តិសុខសង្គម, និងសមាសធាតុកម្មវិធីក្នុងយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម

| ល.រ | កម្មវិធី/របប | សមាសធាតុកម្មវិធី | ស្ថាប័នអនុវត្ត |
|---|---|---|---|
| ១ | កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | ការអភិវឌ្ឍមូលធនមនុស្ស | ក.អ.យ.ក |
| ២ | កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រថ្នាក់បឋមសិក្សា និងមធ្យមសិក្សា | | ក.អ.យ.ក |
| ៣ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ | | ក.ស.អ.យ |
| ៤ | របបប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) | ប្រាក់សោធន | ក.ស.អ.យ |
| ៥ | របបប្រាក់សោធនសម្រាប់អតីតយុទ្ធជន (ប.ជ.អ) | | ក.ស.អ.យ |
| ៦ | របបប្រាក់សោធនសម្រាប់កម្មករនិយោជិត | | ប.ស.ស |
| ៧ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព | សុខមាលភាពរបស់ប្រជាជនងាយរងគ្រោះ | ក.ស.អ.យ |
| ៨ | មូលនិធិជនពិការ (ម.ជ.ព) | | ក.ស.អ.យ |
| ៩ | របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ | ការថែទាំសុខភាព | ប.ស.ស |
| ១០ | របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត | | ប.ស.ស |
| ១១ | មូលនិធិសមធម៌សុខាភិបាល (ម.ធ.ស) | | ទ.ជ.ប / ក.ស.ខ.ល / ប.ស.ស |
| ១២ | របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ | ហានិភ័យការងារ | ប.ស.ស |
| ១៣ | របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត | | ប.ស.ស |
| ១៤ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ | ការឆ្លើយតបនឹងគ្រោះអាសន្ន | ក.ស.អ.យ |
| ១៥ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ | | ក.ស.អ.យ |
| ១៦ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា | | ក.ស.អ.យ |
| ១៧ | *ប្រព័ន្ធស្បៀងបម្រុង | | ក.ស.រ |
| ១៨ | *កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ | | ក.ក.ប |
| ១៩ | *កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករក្រោយការបិទខ្ទប់ | | ក.ក.ប |

* *កម្មវិធីទាំង៣នេះ មិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមនៅឡើយទេ*

* *របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ នឹងដាក់បញ្ចូលក្នុងរបាយការណ៍ក្រោយទទួលបានទិន្នន័យគ្រប់គ្រាន់។*

**បញ្ហាប្រឈម៖** យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមបានកំណត់ឱ្យក្រសួង-ស្ថាប័នដែលជាអង្គភាពរាយការណ៍បញ្ចូលទិន្នន័យឆ្នាំកន្លងមក ដោយចាប់ផ្តើមពីឆ្នាំ២០១៥ និងធ្វើការបែងចែកទិន្នន័យទាំងនេះទៅតាមចរិតលក្ខណៈ និងអត្ថន័យរបស់សូចនាករនីមួយៗ ដូចជាបែងចែកតាមរាជធានីខេត្ត, ភេទរបស់អត្ថគាហក និងប្រភេទនៃការចំណាយជាដើម។ យ៉ាងណាមិញ ការស្វែងរកទិន្នន័យចាស់ៗ ហើយធ្វើការបែងចែកតាមឆ្នាំនីមួយៗ បានផ្តល់ផលលំបាកដល់ជនបង្គោលរបស់អង្គភាពរាយការណ៍ ក្នុងការស្រាវជ្រាវ និងស្វែងរក ដែលកម្មវិធី និងរបបមួយចំនួនមិនទាន់មានប្រព័ន្ធគ្រប់គ្រង និងកត់ត្រាទិន្នន័យជាលក្ខណៈឌីជីថលនៅឡើយ។ ដូចនេះ ទិន្នន័យសូចនាកររបស់កម្មវិធី និងរបបមួយចំនួនមិនទាន់អាចបំពេញបានគ្រប់ជ្រុងជ្រោយតាមការកំណត់ក្នុងយន្តការតាមដាន និងវាយតម្លៃនៅឡើយ។ ក្នុងន័យនេះ, របាយការណ៍នេះបង្ហាញបាននូវសមាសធាតុកម្មវិធីចំនួន៣ គឺ ការថែទាំសុខភាព (២កម្មវិធី/របប), ហានិភ័យការងារ (១របប), និងការឆ្លើយតបនឹងគ្រោះអាសន្ន (៦កម្មវិធី)។ ដោយឡែក សម្រាប់សមាសធាតុកម្មវិធីផ្សេងទៀតពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស, ប្រាក់សោធន, និងសុខុមាលភាពរបស់ប្រជាជនងាយរងគ្រោះ, ក្រុមការងារនឹងរាយការណ៍បន្ថែមទៀតក្រោយទទួលបានទិន្នន័យគ្រប់ជ្រុងជ្រោយ។ ដោយឡែក, សម្រាប់ការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គម របាយការណ៍នេះ នឹងបង្ហាញពីការវិនិយោគ (ចំណាយ) នៅក្នុងប្រព័ន្ធគាំពារសង្គម (ទាំង ៦សមាសធាតុ និង ១៩កម្មវិធី/របប) ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២។

# ២.

# ការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គម

ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវបានបង្កើតឡើងកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ និងមានសមាសភាពមកពី ១២ ក្រសួង-ស្ថាប័ន ដែលមានតួនាទី និងភារៈកិច្ច រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម, រៀបចំ និងបង្កើតក្របខណ្ឌស្ថាប័ន យន្តការអភិបាលកិច្ចល្អ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកម្មវិធីគាំពារសង្គមប្រកបដោយប្រសិទ្ធភាព, ធ្វើសមាហរណកម្ម និងសុខដុមនីយកម្មរបបសន្តិសុខសង្គម និង/ឬកម្មវិធីជាតិជំនួយសង្គមដែលមានស្រាប់ស្របតាមក្របខណ្ឌគោលនយោបាយជាតិ, កៀរគរធនធានហិរញ្ញវត្ថុ និងកសាងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងវិស័យគាំពារសង្គម, និងតាមដាន និងត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

រូបភាពទី១ បង្ហាញពីការវិនិយោគ (ចំណាយ) របស់កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលស្ថិតក្នុងក្របខណ្ឌនៃប្រព័ន្ធគាំពារសង្គមពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២។ យោងតាមទិន្នន័យបង្ហាញថា ការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គមមានការកើនឡើងពី ១% នៃ ផ.ស.ស ក្នុងឆ្នាំ២០១៨ ដល់ ១,៣% ក្នុងឆ្នាំ២០១៩។ ការវិនិយោគនេះមានការកើនឡើងទ្វេដងរហូតដល់ចុងឆ្នាំ២០២២ គឺប្រមាណ ៣,១% នៃផ.ស.ស។ ជាមួយគ្នានេះដែរ, ភាគរយនៃការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គមធៀបនឹងថវិកាជាតិក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដោយបានកើនឡើងពីប្រមាណ ៤,៥% ក្នុងឆ្នាំ២០១៨ ដល់ ១៤% នៃថវិកាជាតិក្នុងឆ្នាំ២០២២។ ជាការកត់សម្គាល់, ចំណាយក្នុងប្រព័ន្ធគាំពារសង្គមមានការកើនឡើងជាខ្លាំងចាប់ពីឆ្នាំ២០២០ ដោយការវិនិយោគនេះ បានបូករួមទាំងចំណាយអន្តរាគមន៍របស់រាជរដ្ឋាភិបាលដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន ក្នុងគោលដៅរក្សាលំនឹងជីវភាពប្រជាជនក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, គ្រោះទឹកជំនន់, និងសម្ពាធអតិផរណា, កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារជាដើម ដោយក្នុងនេះមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ចំនួន៦ ត្រូវបានដាក់ឱ្យអនុវត្តគឺ ១. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, ២. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់, ៣. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងពេលមានសម្ពាធអតិផរណា, ៤. ប្រព័ន្ធស្បៀងបម្រុង, ៥. កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ, និង ៦. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករក្រោយការបិទខ្ទប់។

**រូបភាពទី១** និន្នាការនៃការវិនិយោគ (ចំណាយ) ក្នុងប្រព័ន្ធគាំពារសង្គម




យោងតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥, ប្រព័ន្ធគាំពារសង្គម មានសសរស្តម្ភចំនួនពីរគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ប្រព័ន្ធសន្តិសុខសង្គមមានសមាសធាតុផ្សំចំនួន៥ គឺ សោធន, ថែទាំសុខភាព, ហានិភ័យការងារ, និកម្មភាព, និងពិការភាព។ ដោយឡែក ប្រព័ន្ធជំនួយសង្គមមានសមាសធាតុផ្សំចំនួន៤ គឺ ការឆ្លើយតបនឹងគ្រោះអាសន្ន, ការអភិវឌ្ឍធនធានមនុស្ស, ការបណ្តុះ បណ្តាលវិជ្ជាជីវៈ និងសុខុមាលភាពសម្រាប់ជនងាយរងគ្រោះ។

**រូបភាពទី២** ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម




*ប្រភព៖ សៀវភៅក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥*

យ៉ាងណាមិញ, បច្ចុប្បន្ន យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម មានកម្មវិធី/របបចំនួន១៦ ដែលបានបែងចែកទៅតាមសមាសធាតុចំនួន៦គឺ៖ សោធន, ការថែទាំសុខភាព, ហានិភ័យការងារ, ការឆ្លើយតបនឹងគ្រោះអាសន្ន, ការអភិវឌ្ឍមូលធនមនុស្ស, និងសុខុមាលភាពសម្រាប់ជនងាយរងគ្រោះ (ដូចបានបែងចែកលម្អិតក្នុងតារាងទី១)។ កម្មវិធី/របបទាំងនោះត្រូវបានបែងចែក ទៅតាមសមាសធាតុនីមួយៗ ដែលមានក្នុងប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម ស្របទៅតាមក្របខណ្ឌគោលនយោបាយគាំពារសង្គមកម្ពុជា។

ការវិនិយោគក្នុងប្រព័ន្ធសន្តិសុខសង្គម និងជំនួយសង្គមមានការប្រែប្រួលគួរឱ្យកត់សម្គាល់ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ដូចបានបង្ហាញក្នុងរូបភាពទី៣ និងរូបភាពទី៤ ។ ក្នុងរូបភាពទី៣, ការវិនិយោគក្នុងកម្មវិធីជាតិជំនួយសង្គមមានការកើនឡើងជាខ្លាំងធៀបនឹងផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ដែលបានកើនឡើងពី ០,៧% នៃផ.ស.ស ក្នុងឆ្នាំ២០១៨ ទៅប្រមាណជា ១,៦% ក្នុងឆ្នាំ២០២២។ ចំណែកការវិនិយោគក្នុងប្រព័ន្ធសន្តិសុខសង្គម មានការកើនឡើងពីប្រមាណ ១% នៃផ.ស.ស ក្នុងឆ្នាំ២០១៨ ដល់ ១,៤% ក្នុងឆ្នាំ២០២២ ដែលកំណើននេះហាក់មានការប្រែប្រួលតិចតួចពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ក្នុងរង្វង់ ១,៥% នៃផ.ស.ស។

**រូបភាពទី៣** ការវិនិយោគក្នុងប្រព័ន្ធជំនួយសង្គម និងសន្តិសុខសង្គម (%ផ.ស.ស)




**រូបភាពទី៤** ការវិនិយោគក្នុងប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម



ដោយឡែក, រូបភាពទី៤ បានបង្ហាញពីការរួមចំណែកនៃការវិនិយោគរបស់កម្មវិធីជាតិជំនួយសង្គមក្នុងប្រព័ន្ធគាំពារសង្គមប្រៀបធៀបនឹងការវិនិយោគនៅក្នុងប្រព័ន្ធសន្តិសុខសង្គម។ ជាការសង្កេត, ការរួមចំណែកនៃការវិនិយោគរបស់កម្មវិធីជាតិជំនួយសង្គមក្នុងប្រព័ន្ធគាំពារសង្គមមានការកើនឡើង ពីប្រមាណ ៧% ក្នុងឆ្នាំ២០១៨ ដល់ប្រមាណជិត ៥៣% ក្នុងឆ្នាំ២០២២។ ជាការកត់សម្គាល់, ការរួមចំណែកនេះមានការកើនឡើងជាខ្លាំងក្នុងឆ្នាំ២០២០ បន្ទាប់ពីរាជរដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ, និងកម្មវិធីចំនួន២ ទៀតក្នុងឆ្នាំ២០២២ គឺកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់, និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា។ ការដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គមទាំង៤ ខាងលើ បានបង្កើនការរួមចំណែកនៃវិនិយោគរបស់ប្រព័ន្ធជំនួយសង្គមទៅប្រមាណ ៥៣% នៅក្នុងក្របខណ្ឌប្រព័ន្ធគាំពារសង្គមកម្ពុជាទាំងមូលនៅឆ្នាំ២០២២។

ប្រព័ន្ធជំនួយសង្គមក្នុងឆ្នាំ២០២២ មានកម្មវិធីចំនួន១១ ដូចបានបង្ហាញនៅក្នុងរូបភាពទី៥។ ក្នុងចំណោមកម្មវិធីទាំងអស់ក្នុងប្រព័ន្ធជំនួយសង្គម, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធប្រឆាំនឹងជំងឺកូវីដ-១៩ ជាកម្មវិធីដែលរាជរដ្ឋាភិបាលបានវិនិយោគថវិកាប្រមាណ ៧៦,៥% នៃថវិកាដែលបានចំណាយសរុបក្នុងប្រព័ន្ធជំនួយសង្គម។ ក្រៅពីនេះ, កម្មវិធីអាហារូបករណ៍សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបានចូលរួមប្រមាណ ៣,៣%, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ ប្រមាណ ២,៤%, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងពេលមានសម្ពាធអតិផរណា ប្រមាណ ១,៩%, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ប្រមាណ ១,៧%, មូលនិធិជនពិការ (ម.ជ.ព) ប្រមាណ ០,៥%, កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ប្រមាណ ០,៥%, និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព (តាមច្បាប់ថវិកា) បានចូលរួមប្រមាណ ០,២% នៃប្រព័ន្ធជំនួយសង្គមទាំងមូល និងកម្មវិធីចំនួន៣ ផ្សេងទៀតដែលជាកម្មវិធីអន្តរាគមន៍បន្ថែមរបស់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន គឺ កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករក្រោយការបិទខ្ទប់ចូលរួមចំណែកប្រមាណជិត ១២%, និងប្រព័ន្ធស្បៀងបម្រុងប្រមាណ ១,១%។

## រូបភាពទី៥ ការវិនិយោគតាមកម្មវិធីក្នុងប្រព័ន្ធជំនួយសង្គម ឆ្នាំ២០២២ (%)




ដោយឡែក, រូបភាពទី៦ បង្ហាញពីការវិនិយោគនៅក្នុងប្រព័ន្ធសន្តិសុខសង្គម ក្នុងឆ្នាំ២០២២ ដែលក្នុងនោះមាន ៦ របប និងមូលនិធិចំនួន១។ យោងតាមរូបភាពទី៦, ការវិនិយោគធំជាងគេក្នុងប្រព័ន្ធសន្តិសុខសង្គម គឺក្នុងរបបប្រាក់សោធនសម្រាប់អតីតយុទ្ធជន (ប.ជ.អ) ដែលគ្របដណ្តប់ប្រមាណ ៤៤,៨% នៃថវិកាសរុបក្នុងប្រព័ន្ធសន្តិសុខសង្គម។ ក្រៅពីនេះ, របបប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) បានចូលរួមប្រមាណ ២៩,៥%, របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ប្រមាណ ១៥%, មូលនិធិសមធម៌សុខាភិបាលប្រមាណ ៦,១%, របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈប្រមាណ ៣,៤%, របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ប្រមាណ ១,២%, និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈបានចូលរួមប្រមាណ ០,០២% នៃថវិកាចំណាយសរុបក្នុងប្រព័ន្ធសន្តិសុខសង្គម។

## រូបភាពទី៦ ការវិនិយោគតាមរបប/មូលនិធិ ក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ២០២២ (%)



# ៣.

# ការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម

ក្នុងគោលបំណងរក្សាសុខុមាលភាព ក៏ដូចជាលំនឹងជីវភាពរបស់ប្រជាជន ស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម, រាជរដ្ឋាភិបាលបានដាក់ចេញនូវរបបសន្តិសុខសង្គម និងកម្មវិធីជំនួយសង្គមថ្មីៗមួយចំនួន ជាពិសេសកម្មវិធីជំនួយសង្គមសម្រាប់ការឆ្លើយតបភ្លាមៗនឹងគ្រោះអាសន្ន សម្រាប់ក្រុមប្រជាជនក្រីក្រ និងក្រុមប្រជាជនគោលដៅថ្មីដែលងាយរងគ្រោះ ដើម្បីទទួលអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម។ ជាលទ្ធផលនៃការវិនិយោគរបស់រាជរដ្ឋាភិបាល លើការកសាងប្រព័ន្ធគាំពារសង្គមក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ, អត្រានៃការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គមមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយបានកើនឡើងពីប្រមាណ ២៦,៥% ក្នុងឆ្នាំ២០១៨ ទៅប្រមាណ ៤២% នៃចំនួនប្រជាជនសរុប ក្នុងឆ្នាំ២០២២។ អត្រានេះមានការកើនឡើងខ្លាំងក្នុងឆ្នាំ២០២២ ដោយរាជរដ្ឋាភិបាលបានដាក់ក្រុមប្រជាជនគោលដៅថ្មី គឺគ្រួសារដែលងាយរងហានិភ័យ (សមាជិកគ្រួសារដែលរស់នៅក្បែរបន្ទាត់ភាពក្រីក្រ) ចូលក្នុងកម្មវិធីនៃប្រព័ន្ធគាំពារសង្គម។ ក្នុងទិដ្ឋភាពរួម, ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២ និន្នាការនៃចំនួនប្រជាជនដែលទទួលបានការគ្របដណ្តប់ក្នុងប្រព័ន្ធគាំពារសង្គម មានការកើនឡើងជាលំដាប់ដល់ប្រមាណ ១៤,៦% ជាមធ្យមក្នុងមួយឆ្នាំ (សូមមើលរូបភាពទី៧)។

**រូបភាពទី៧** អត្រាគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម (% ចំនួនប្រជាជនសរុប)




**ការគ្របដណ្តប់នេះរួមមាន៖ សមាជិកមូលនិធិសមធម៌, សមាជិក ប.ស.ស (របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព), និងសមាជិកគ្រួសារងាយរងហានិភ័យ*

# ៣.១. ផ្នែកថែទាំសុខភាព

## ៣.១.១. វឌ្ឍនភាពនៃការអនុវត្តមូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារក្រីក្រ

**សាវតារ៖**

មូលនិធិសមធម៌សុខាភិបាលត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០០០ ក្រោមកិច្ចផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ការប្រើប្រាស់សេវាសុខាភិបាលដល់ប្រជាជន ជាពិសេសជនក្រីក្រ[១] ដែលស្របតាមគោលការណ៍ "**មិនបោះបង់ពលរដ្ឋណាម្នាក់**"។ ក្នុងឆ្នាំ២០០៦, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល បានចេញសេចក្តីប្រកាសរួម ស្តីពីការវិភាជន៍ថវិកាជាតិជូនមូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីបង់ថ្លៃសេវាជួសគ្រួសារក្រីក្រ។ រហូតដល់បច្ចុប្បន្ន, តាមរយៈការប្រើប្រាស់បណ្ណសមធម៌ ឬបណ្ណក្រីក្រ (Pre-ID/IDPoor) ដែលចេញដោយក្រសួងផែនការ និងបណ្ណអទិភាព (Post-ID/PAC Card) ដែលចេញដោយភ្នាក់ងារលើកកម្ពស់មូលនិធិសមធម៌ (នៅតាមមូលដ្ឋានសុខាភិបាល), ប្រជាជនក្រីក្រនឹងទទួលបានសេវាពិគ្រោះជំងឺក្រៅ និងសម្រាកពេទ្យ ឬសម្រាលកូន ដោយឥតគិតថ្លៃ (ដោយរាជរដ្ឋាភិបាលទទួលបន្ទុកបង់ជំនួស)។ ក្រៅពីនេះ អ្នកជំងឺសម្រាកពេទ្យដែលមានលិខិតបញ្ជូន និងស្ត្រីសម្រាលកូន នឹងទទួលបានប្រាក់ឧបត្ថម្ភផ្សេងៗទៀតដូចជាសោហ៊ុយធ្វើដំណើរ, ថ្លៃអាហារអ្នកជំងឺ, និងបុណ្យសព[២]។

**ចំនួនអត្ថគាហកៈ**

អត្ថគាហកនៃមូលនិធិសមធម៌សម្រាប់គ្រួសារក្រីក្រសំដៅដល់អ្នកដែលមានបណ្ណសមធម៌ ឬបណ្ណអទិភាព។ បើគិតពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២, និន្នាការនៃចំនួនអត្ថគាហកនៃរបបនេះមានការកើនឡើងជាលំដាប់ប្រមាណ ៥,៧% ជាមធ្យមក្នុងមួយឆ្នាំ។ ក្នុងឆ្នាំ២០១៨, អត្ថគាហកសរុបនៃមូលនិធិនេះមានចំនួនសរុបប្រមាណ ២លាន ៥សែននាក់ ដែលគ្របដណ្តប់ប្រមាណ ១៥,៨% នៃប្រជាជនសរុប ដែលចំនួននេះបានកើនឡើងដល់ប្រមាណជាង ៣លាន ១សែននាក់ និងគ្របដណ្តប់ប្រមាណ ១៨,៦% នៃប្រជាជនសរុប ក្នុងឆ្នាំ២០២២ (សូមមើលរូបភាពទី៨)។

១ ប្រភព៖ ក្រសួងសុខាភិបាល
២ ប្រភព៖ ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល (បច្ចុប្បន្នជា ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ)

**រូបភាពទី៨** ចំនួនអត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារក្រីក្រ




**អត្រានៃការប្រើប្រាស់៖**

អត្រានៃការប្រើប្រាស់នៃមូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារក្រីក្រ សំដៅដល់ចំនួនដងនៃការប្រើប្រាស់សេវាពិគ្រោះជំងឺក្រៅ សម្រាកពេទ្យ និងសម្រាលកូន ដោយឥតគិតថ្លៃរបស់អត្ថគាហកនៃមូលនិធិនេះ នៅតាមមូលដ្ឋានសុខាភិបាលនានា ដោយប្រើប្រាស់បណ្ណសមធម៌ ឬបណ្ណក្រីក្រ និងបណ្ណអាទិភាព។ បើគិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២, អត្រានៃការប្រើប្រាស់នេះមានភាពប្រែប្រួលទៅតាមឆ្នាំនីមួយៗ។ ក្នុងឆ្នាំ២០១៨, អត្ថគាហកនៃមូលនិធិនេះបានប្រើប្រាស់សេវាពិគ្រោះជំងឺក្រៅ សម្រាកពេទ្យ និងសម្រាលកូននៅតាមមូលដ្ឋានសុខាភិបាលនានា ជាមធ្យមប្រមាណ ១,១ ដងក្នុងមួយឆ្នាំ ហើយបានកើនឡើងដល់ប្រមាណ ១,១៦ ដងក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០១៩។ អត្រានៃការប្រើប្រាស់នេះ មានប្រមាណ ១,១ ដងក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០២០ និង ១,០ ដងក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ ដូចបានបង្ហាញក្នុងរូបភាពទី៩។

**រូបភាពទី៩** អត្រានៃការប្រើប្រាស់របស់អត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារក្រីក្រ



## ៣.១.២. វឌ្ឍនភាពនៃការអនុវត្តមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ

**សាវតារ៖**

មូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ គឺជាការផ្តល់សេវាពិគ្រោះជំងឺក្រៅ, សម្រាកពេទ្យ និងសម្រាលកូន ដោយឥតគិតថ្លៃ (ដោយរាជរដ្ឋាភិបាលទទួលបន្ទុកបង់ជំនួស) ដល់កម្មករនិយោជិតក្រៅប្រព័ន្ធ មេភូមិ ក្រុមប្រឹក្សាឃុំ កីឡាករ កីឡាការនី កម្មករធាក់ស៊ីក្លូ បុគ្គលិក និងអ្នកជំនាញដោះមីន តាមរយៈការប្រើប្រាស់បណ្ណមូលនិធិសមធម៌សុខាភិបាល (បណ្ណពណ៌លឿង និងបណ្ណពណ៌ស្វាយ)[៣]។

**ចំនួនអត្ថគាហកៈ**

ចំនួនអត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃសំដៅដល់អ្នកដែលមានបណ្ណពណ៌លឿង និងបណ្ណពណ៌ស្វាយ។ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២, ចំនួនអត្ថគាហកនៃមូលនិធិនេះមាននិន្នាការកើនឡើងបន្តិចបន្តួច ក្នុងអត្រាកំណើនជាមធ្យមប្រមាណ ៣% ក្នុងមួយឆ្នាំ។ ជាក់ស្តែង ចំនួនអត្ថគាហកសរុបមានប្រមាណ ៨ម៉ឺន ៨ពាន់នាក់ ក្នុងឆ្នាំ២០១៩ ឬស្មើនឹង ០,៥% នៃចំនួនប្រជាជនសរុប, ៩ម៉ឺន ៣ពាន់នាក់ ក្នុងឆ្នាំ២០២០, ៩ម៉ឺន ៤ពាន់នាក់ ក្នុងឆ្នាំ២០២១, និង៩ម៉ឺន ៦ពាន់នាក់ ឬស្មើនឹង ០,៦% នៃចំនួនប្រជាជនសរុប ក្នុងឆ្នាំ២០២២ (សូមមើលរូបភាពទី១០)។ យ៉ាងណាមិញ, ចំនួនអត្ថគាហកនៃមូលនិធិនេះភាគច្រើនជាបុរស។ ដូចបានបង្ហាញក្នុងរូបភាពទី១១, ចំនួនអត្ថគាហកជាបុរសមានរហូតដល់ប្រមាណ ៧៨% ក្នុងឆ្នាំ២០២២។

**រូបភាពទី១០** ចំនួនអត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ




**រូបភាពទី១១** វិសមភាពភេទនៃអត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ




៣ ប្រភព៖ ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ

**អត្រានៃការប្រើប្រាស់៖**

អត្រានៃការប្រើប្រាស់នៃមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ សំដៅដល់ចំនួនដងនៃការប្រើប្រាស់សេវាពិគ្រោះជំងឺក្រៅ សម្រាកពេទ្យ និងសម្រាលកូន ដោយឥតគិតថ្លៃរបស់អត្ថគាហកនៃមូលនិធិនេះ នៅតាមមូលដ្ឋានសុខាភិបាលនានា ដោយប្រើប្រាស់បណ្ណពណ៌លឿង និងបណ្ណពណ៌ស្វាយ។ ស្រដៀងគ្នានឹងអត្រានៃការប្រើប្រាស់នៃមូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារក្រីក្រដែរ, អត្រានៃការប្រើប្រាស់របស់អត្ថគាហកនៃមូលនិធិសមធម៌សម្រាប់ក្រុមប្រជាជនដទៃពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ មានភាពប្រែប្រួលទៅតាមឆ្នាំនីមួយៗ។ ក្នុងឆ្នាំ២០១៩, អត្រានៃការប្រើប្រាស់ របស់អត្ថគាហកនៃមូលនិធិនេះ មានជាមធ្យមប្រមាណ ០,៧៦ ដងក្នុងមួយឆ្នាំ, ឆ្នាំ២០២០ មានប្រមាណ ០,៨៥ ដងក្នុងមួយឆ្នាំ, ឆ្នាំ២០២១ មានប្រមាណ ០,៧៨ ដងក្នុងមួយឆ្នាំ, និងឆ្នាំ២០២២ មានប្រមាណ ០,៨១ ដងក្នុងមួយឆ្នាំ ដូចបានបង្ហាញក្នុងរូបភាពទី១២ ។

**រូបភាពទី១២** អត្រានៃការប្រើប្រាស់របស់អត្ថគាហកនៃមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ




## ៣.១.៣. វឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត

**សាវតារ៖**

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ជារបបសន្តិសុខសង្គមមួយដែលធានារ៉ាប់រងសុខភាពសង្គម សម្រាប់បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្ដីពីការងារ និងបានចុះបញ្ជិកាក្នុង ប.ស.ស សម្រាប់របបនេះ តាមរយៈការបង់ភាគទានប្រចាំខែតាមច្បាប់ដែលបានកំណត់។

**ចំនួនអត្ថគាហកៈ**

បើគិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២, ចំនួនអត្ថគាហកនៃរបបនេះ មាននិន្នាការកើនឡើងជាលំដាប់ក្នុងអត្រាកំណើនជាមធ្យមប្រមាណ ៤,៥% ក្នុងមួយឆ្នាំ ដែលកំណើននេះគឺស្របពេលដែលចំនួននិយោជក ឬក្រុមហ៊ុន សហគ្រាសដែលបានចុះបញ្ជិកាក្នុង ប.ស.ស មានកាន់តែច្រើន។ ជាក់ស្ដែង ចំនួនអត្ថគាហកកើនឡើងបន្តិចម្តងៗពីជាង ១លាន ២សែននាក់ ក្នុងឆ្នាំ២០១៨ ដល់ជាង ១លាន ៤សែននាក់ ក្នុងរយៈពេល ៤ឆ្នាំបន្ទាប់ ដែលចំនួននេះស្មើនឹងប្រមាណ ១៥,៩% នៃកម្លាំងពលកម្មសរុប (សូមមើលរូបភាពទី១៣)។ ក្នុងឆ្នាំ២០២២, និយោជក ឬក្រុមហ៊ុន សហគ្រាសដែលបានចុះបញ្ជីកាក្នុង ប.ស.ស សម្រាប់របបនេះ មានចំនួនរហូតដល់ ១៣ ៩៧២ ដែលចំនួននេះបានកើនឡើងចំនួនប្រមាណ ៤៧% ធៀបនឹងឆ្នាំ២០១៨។

**រូបភាពទី១៣** ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មកនិយោជិត




**រូបភាពទី១៤** បច្ចុប្បន្នភាពនៃចំនួនសហគ្រាសនរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត




ដូចបានបង្ហាញក្នុងរូបភាពទី១៥, នៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតភាគច្រើនជាស្ត្រី។ ជាក់ស្ដែងនៅក្នុងឆ្នាំ២០២២, ចំនួនអត្ថគាហកជាស្ត្រីមានរហូតដល់ប្រមាណ ៦២% ឬចំនួន ៨៩៥ ៥៣៤ នាក់ ចំណែកបុរសវិញមានត្រឹមតែ ៥៣៨ ៨៧៣ នាក់។ រូបភាពទី១៦ ដែលបង្ហាញពីរបាយនៃចំនួនអត្ថគាហកនៃរបបនេះតាមតំបន់នីមួយៗ បានស្ដែងឱ្យឃើញថាប្រមាណជាងពាក់កណ្ដាលនៃចំនួនអត្ថគាហកនេះទាំងអស់ ជាអ្នកបំពេញការងារនៅរាជធានីភ្នំពេញ។ អ្នកដែលបំពេញការងារនៅរាជធានីភ្នំពេញមានអត្ថគាហកចំនួន ៧២៣ ៣០៣ នាក់ ឬប្រមាណ ៥០,៥%, ខេត្តកណ្ដាលមានចំនួនប្រមាណ ១០,៦%, ខេត្តកំពង់ស្ពឺមានចំនួនប្រមាណ ៩,៨%, ស្វាយរៀង ៥,៩%, តាកែវ ៤,១%, កំពង់ឆ្នាំង ៣,៦%, និងកំពង់ចាម ២,៤%, ខណៈខេត្តនីមួយៗផ្សេងទៀតមានចំនួនប្រមាណ ១% ឬតិចជាងនេះ ធៀបនឹងចំនួនអត្ថគាហកសរុបទាំងអស់នៃរបបនេះក្នុងប្រទេសកម្ពុជា។

**រូបភាពទី១៥** ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត (តាមភេទ)




**រូបភាពទី១៦** ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតឆ្នាំ២០២២(តាមរាជធានី-ខេត្ត)




## អត្រានៃការប្រើប្រាស់៖

អត្រានៃការប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រនៅតាមមូលដ្ឋានសុខាភិបាលរបស់អត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត មានការកើនឡើងជាលំដាប់ជាពិសេសក្នុងឆ្នាំ២០២០។ អត្រានៃការប្រើប្រាស់នេះ សំដៅលើចំនួនដងជាមធ្យមដែលអត្ថគាហកម្នាក់ៗនៃរបបនេះ បានប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រនៅតាមមូលដ្ឋានសុខាភិបាលដែលទទួលស្គាល់ដោយ ប.ស.ស។ ក្នុងន័យនេះ, ក្នុងឆ្នាំ២០១៨ អត្ថគាហកម្នាក់ៗបានប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រជាមធ្យមប្រមាណ ១ដងក្នុងមួយឆ្នាំ ហើយអត្រានៃការប្រើប្រាស់នេះ មានទំនោរកើនឡើងជាបន្តបន្ទាប់ក្នុងឆ្នាំបន្ទាប់ជាពិសេសក្នុងឆ្នាំ២០២០ (២,៣៤ ដងក្នុងមួយឆ្នាំ)។ (សូមមើលរូបភាពទី១៧)

**រូបភាពទី១៧** អត្រានៃការប្រើប្រាស់របស់អត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត



**តាវកាលិក បានផ្ទេរ៖**

តាវកាលិកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត សំដៅដល់ការផ្តល់កញ្ចប់តាវកាលិកសុខភាព និងសេវាបង្ការផ្សេងៗ ដែលក្នុងនោះ រួមមានសេវាថែទាំ និងព្យាបាលវេជ្ជសាស្ត្រ, ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ, និងប្រាក់បំណាច់មាតុភាព។ ក្នុងចន្លោះឆ្នាំ២០១៨ ដល់ឆ្នាំ២០២០, និន្នាការនៃការផ្ទេរតាវកាលិកដល់អត្ថគាហកនៃរបបនេះមានការកើនឡើងយ៉ាងខ្លាំង ស្របពេលដែលអត្រាប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រមាននិន្នាការកើនឡើងដូចគ្នាក្នុងអំឡុងឆ្នាំទាំងនេះ, ដោយជាមធ្យមការផ្ទេរតាវកាលិកមានកំណើនប្រមាណ ៦១% ក្នុងមួយឆ្នាំ ដូចបានបង្ហាញក្នុងរូបភាពទី១៨ ។ ជាក់ស្តែង, ការផ្ទេរតាវកាលិកក្នុងឆ្នាំ២០២០ មានរហូតដល់ ១៦៩ ៣៩៥ លានរៀល។

**រូបភាពទី១៨** ថវិកាដែលបានផ្ទេរក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត( លានរៀល )




**រូបភាពទី១៩** ថវិកាដែលបានផ្ទេរក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតឆ្នាំ២០២២( តាមរាជធានី-ខេត្ត )



# ៣.២. ផ្នែកហានិភ័យការងារ

## ៣.២.១. វឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់កម្មករនិយោជិត

**សាវតារ៖**

របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត គឺជារបបសន្តិសុខសង្គមមួយ ដែលធានារ៉ាប់រងផ្ទេរតាវកាលិកដល់សមាជិករបស់ខ្លួន ឬជាកម្មករនិយោជិតក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្តីពីការងារ ដែលបានចុះបញ្ជិកាជាមួយ ប.ស.ស សម្រាប់របបនេះតាមរយៈការបង់ភាគទានប្រចាំខែតាមច្បាប់ដែលបានកំណត់។

**ចំនួនអត្ថគាហក៖**

ដោយគិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២, ចំនួនអត្ថគាហកនៃរបបនេះមាននិន្នាការកើនឡើងជាលំដាប់ ក្នុងអត្រាកំណើនជាមធ្យមប្រមាណ ៥,៣% ក្នុងមួយឆ្នាំ ខណៈនិយោជក ឬក្រុមហ៊ុន-សហគ្រាសដែលបានចុះបញ្ជិកាក្នុងប.ស.ស សម្រាប់របបនេះ មានការកើនឡើងដូចគ្នា។ ជាក់ស្តែង ចំនួនអត្ថគាហកកើនឡើងពីជាង ១លាន ២សែននាក់ ក្នុងឆ្នាំ២០១៨ ដល់ជាង ១លាន ៤សែននាក់ ក្នុងរយៈពេល ៤ឆ្នាំបន្ទាប់ ឬស្មើនឹង ១៥,៩% នៃកម្លាំងពលកម្មសរុប។ (សូមមើលរូបភាពទី២០ និងរូបភាពទី២១)

**រូបភាពទី២០** ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត




**រូបភាពទី២១** បច្ចុប្បន្នភាពនៃចំនួនសហគ្រាសនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត



ស្របជៀងគ្នានឹងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតដែរ, ចំនួនអត្ថគាហកនៃរបបនេះភាគច្រើនជាស្ត្រី។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២២, ចំនួនអត្ថគាហកជាស្ត្រីមានប្រមាណ ៦២% ឬចំនួន ៨៩៥ ៥៣៨នាក់ ចំណែកអត្ថគាហកជាបុរសវិញមានចំនួនប្រមាណត្រឹមតែ ៣៨%។ ប្រមាណជាជាងពាក់កណ្តាលនៃចំនួនអត្ថគាហកទាំងអស់បំពេញការងារនៅរាជធានីភ្នំពេញ។ អត្ថគាហកដែលបំពេញការងារនៅរាជធានីភ្នំពេញមានចំនួន ៧២៣ ៩១៧នាក់ ឬប្រមាណរហូតដល់ ៥០,៥% នៃចំនួនអត្ថគាហកទាំងអស់នៃរបបនេះក្នុងប្រទេសកម្ពុជា។ ខេត្តកណ្តាលមានអត្ថគាហកប្រមាណ ១០,៥%, កំពង់ស្ពឺមានប្រមាណ ៩,៨%, ស្វាយរៀងមានប្រមាណ ៦%, តាកែវមានប្រមាណ ៤,១%, កំពង់ឆ្នាំងមានប្រមាណ ៣,៦%, សៀមរាបមាន ១,៤%, កំពតមាន ១,២%, ខណៈខេត្តនីមួយៗផ្សេងទៀតមានអត្ថគាហកសរុបប្រមាណ ១% ឬ តិចជាងនេះ ធៀបនឹងចំនួនអត្ថគាហកសរុប។ (សូមមើលរូបភាពទី២២ និងរូបភាពទី២៣)

**រូបភាពទី២២** ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត (តាមភេទ)




**រូបភាពទី២៣** ចំនួនអត្ថគាហកនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ឆ្នាំ២០២២ (តាមរាជធានី-ខេត្ត)




**តាវកាលិកបានផ្ទេរ**

នៅពេលទទួលរងហានិភ័យការងារ, កម្មករនិយោជិតទាំងអស់នៃសហគ្រាស និងគ្រឹះស្ថានដែលបានចុះបញ្ជិកាជាមួយ ប.ស.ស មានសិទ្ធទទួលបានតាវកាលិកហានិភ័យការងារទៅតាមកម្រិតនៃគ្រោះថ្នាក់ការងារ។ តាវកាលិកទាំងនេះ រួមមាន សេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រនៅតាមមូលដ្ឋានសុខាភិបាលដែលទទួលស្គាល់ដោយ ប.ស.ស, ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន, ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍, វិភាជជាសោហ៊ុយបូជាសព, តាវកាលិកឧត្តរជីវី, និងសេវាបុនរីតិសម្បទា។ យ៉ាងណាមិញ, ចំនួន

តាវកាលិកសរុបដែលបានផ្ទេរក្នុងរបបហានិភ័យការងារនេះ អាស្រ័យលើចំនួនករណីហានិភ័យការងារដែលបានកើតឡើង និងបានជូនដំណឹងដល់ ប.ស.ស ដោយនិយោជក។ ដូចបានបង្ហាញក្នុងរូបភាពទី២៤, ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២១ ចំនួនតាវកាលិកសរុបដែលបានផ្ទេរក្នុងរបបនេះ មាននិន្នាការថយចុះ, ដោយជាមធ្យម ការថយចុះមានប្រមាណ ១៤,៨% ក្នុងមួយឆ្នាំ។ ដោយឡែក, អត្រានៃការផ្ទេរតាវកាលិកនៃរបបនេះមានការកើនឡើងវិញចំនួនប្រមាណ ១៥,៦% នៅឆ្នាំ២០២២ បើប្រៀបធៀបនឹងឆ្នាំ២០២១។ ក្នុងចំណោមរាជធានី-ខេត្តទាំងអស់, រាជធានីភ្នំពេញមានការផ្ទេរតាវកាលិកច្រើនជាងគេក្នុងឆ្នាំ២០២២ ដោយអត្រានៃការផ្ទេរសរុបក្នុងឆ្នាំនេះមានរហូតដល់ប្រមាណ ៦១,៥% ឬប្រមាណ ៤ ៨២៦ លានរៀល នៃការផ្ទេរតាវកាលិកសរុបនៃរបបនេះក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំនេះដដែល, ការផ្ទេរតាវកាលិកក្នុងខេត្តព្រះសីហនុមានប្រមាណ ១៤,៩%, ខេត្តកំពង់ស្ពឺមានប្រមាណ ៨,៨%, ស្វាយរៀងមានប្រមាណ ៦,៣%, កណ្ដាលមានប្រមាណ ២,៨%, កំពង់ឆ្នាំងមានប្រមាណ ២%, តាកែវ និងកំពង់ចាមមានប្រមាណ ១,៣% ខណៈខេត្តនីមួយៗផ្សេងទៀតមានប្រមាណ ១% ឬតិចជាងនេះ ធៀបនឹងថវិកាដែលបានផ្ទេរសរុប។ (សូមមើលរូបភាពទី២៥)

**រូបភាពទី២៤** ថវិកាបានផ្ទេរក្នុងរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត (លានរៀល)




**រូបភាពទី២៥** ថវិកាបានផ្ទេរក្នុងរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត (តាមរាជធានី-ខេត្ត)



# ៣.៣. ការឆ្លើយតបនឹងគ្រោះអាសន្ន

ក្នុងគោលបំណងធានាបាននូវសុខុមាលភាពប្រជាជន, សន្តិសុខប្រាក់ចំណូល, និងបញ្ចៀសនូវការធ្លាក់ចូលក្នុងភាពក្រីក្រធ្ងន់ធ្ងររបស់ប្រជាជន ជាពិសេសខណៈដែលប្រទេសកម្ពុជា ក៏ដូចជាពិភពលោកកំពុងប្រឈមខ្លាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់ទាំងក្នុងវិស័យសុខាភិបាល និងវិស័យសេដ្ឋកិច្ច-សង្គម។ ការធ្វើអន្តរាគមន៍ក្នុងវិស័យសុខាភិបាល តាមរយៈការខិតខំរៀបចំក្រុមការងារ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត, ការរៀបចំបង្កើតមណ្ឌលចត្តាឡីស័កជាច្រើនកន្លែងដើម្បីឆ្លើយតបនឹងការកើនឡើងនៃអ្នកជំងឺកូវីដ-១៩, ជាពិសេសការស្វែងរកវ៉ាក់សាំងសម្រាប់ផ្តល់ជូនប្រជាជន, បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលលើអាយុជីវិតប្រជាជនកម្ពុជា។ បន្ថែមពីនេះ, ក្នុងគោលបំណងរក្សាឱ្យបានលំនឹងជីវភាពប្រជាជនជាពិសេសគ្រួសារក្រីក្រ និងងាយរងគ្រោះ រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាអតីតនាយករដ្ឋមន្ត្រី បានដាក់ចេញនូវកម្មវិធី និងអន្តរាគមន៍ជាច្រើន និងជាបន្តបន្ទាប់ទាំងក្នុងពេលបិទខ្ទប់, និងក្រោយពេលបិទខ្ទប់ ដោយក្នុងនោះមានកម្មវិធីធំៗចំនួន៦គឺ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា, កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករក្រោយការបិទខ្ទប់, និងប្រព័ន្ធស្បៀងបម្រុង។

## ៣.៣.១. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

នាចុងឆ្នាំ២០១៩ ពិភពលោកទាំងមូលបានចាប់ផ្តើមប្រឈមនឹងការផ្ទុះឡើងនៃជំងឺកូវីដ-១៩ បង្កជាភាពរាំងស្ទះ និងប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការសេដ្ឋកិច្ច-សង្គម ដោយសារមានការបិទខ្ទប់តាមតំបន់, ការបិទព្រំដែន និងច្រកចេញចូលក្រៅប្រទេស។ ក្នុងគោលដៅរក្សាឱ្យបាននូវស្ថេរភាពសង្គម ជាពិសេសលំនឹងជីវភាពរបស់ប្រជាជន, រាជរដ្ឋាភិបាលបានដាក់ចេញនូវអន្តរាគមន៍បន្ទាន់តាមរយៈការដាក់ ឱ្យអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចាប់តាំងពីខែមិថុនា ឆ្នាំ២០២០។ ក្រុមគោលដៅជាប្រជាជនក្រីក្រ (គ្រួសារក្រីក្រ) ដែលមានឈ្មោះក្នុងប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងងាយរងគ្រោះនៅប្រទេសកម្ពុជាបានទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែដោយផ្ទាល់ពីរាជរដ្ឋាភិបាលតាមរយៈកម្មវិធីនេះ។ នៅក្នុងការអនុវត្តកម្មវិធីនេះ, ក្រសួងផែនការ ដើរតួនាទីជាអ្នកកំណត់អត្តសញ្ញាណប្រជាជនក្រីក្រ, ចំណែកមូលនិធិជាតិជំនួយសង្គមនៃក្រសួងសង្គមកិច្ច

អតីតយុទ្ធជន និងយុវនីតិសម្បទា ដើរតួនាទីជាអ្នកបើកផ្តល់ (ផ្ទេរ) សាច់ប្រាក់ ដោយប្រើប្រាស់យន្តការធនាគារដែលមានស្រាប់។

ចាប់ពីខែមិថុនា ឆ្នាំ២០២០ រហូតមកដល់ដំណាច់ឆ្នាំ២០២៣ ថវិកាប្រមាណ ៥ ០៩៩ ៨០៤,៣ លានរៀល (ប្រមាណ ១ ២៤៣,៨៥ លានដុល្លារអាម៉េរិក) ត្រូវបានរាជរដ្ឋាភិបាលផ្ទេរជូនគ្រួសារប្រជាជនក្រីក្រ តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។ រូបភាពទី២៦ បង្ហាញថា រាជរដ្ឋាភិបាលវិភាជន៍ថវិកាជាតិប្រមាណ ៥% ក្នុងឆ្នាំ២០២១ និងប្រមាណ ៥,៦% ក្នុងឆ្នាំ២០២២ ដើម្បីផ្តល់ប្រាក់ឧបត្ថម្ភជូនប្រជាជនក្រីក្រ។

**រូបភាពទី២៦** ថវិកាចំណាយប្រចាំឆ្នាំ ពីឆមាសទី២ ឆ្នាំ២០២០ ដល់ដំណាច់ឆ្នាំ២០២៣




រូបភាពទី២៧ បង្ហាញអំពីចំនួនគ្រួសារ, ចំនួនប្រជាជនក្រីក្រ, និងចំនួនថវិកា ដែលរាជរដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភជូនក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ ដើម្បីធានាបាននូវលំនឹងជីវភាពរបស់គ្រួសារប្រជាជនក្រីក្រ។ យោងតាមរូបភាពនេះ ក្នុងខែធ្នូ ឆ្នាំ២០២០ រាជរដ្ឋាភិបាលបានចំណាយថវិកាប្រមាណ ១២២ប៊ីលានរៀល ដើម្បីផ្តល់ជូនគ្រួសារប្រមាណជាង ៦៨ម៉ឺនគ្រួសារ ដែលមានសមាជិកចំនួនប្រមាណ ២លាន ៧សែននាក់ ប្រហាក់ប្រហែលនឹង ១៦,៧% នៃចំនួនប្រជាជនសរុបនៅក្នុងប្រទេស។ ចំនួនអត្ថគាហកក្នុងកម្មវិធីនេះបានកើនឡើង ក្នុងខែធ្នូ ឆ្នាំ២០២២ ដែលគ្របដណ្តប់ប្រមាណ ១៦,៨% នៃប្រជាជនសរុប។ ការគ្របដណ្តប់នេះបានថយចុះមកវិញបន្តិចមកត្រឹម ១៦,៥% នៃចំនួនប្រជាជនសរុប ក្នុងខែធ្នូ ឆ្នាំ២០២៣។ ជារួម, គិតចាប់ពីខែមិថុនា ឆ្នាំ២០២០ រហូតដល់ ដំណាច់ឆ្នាំ២០២៣ រាជរដ្ឋាភិបាល

បានចំណាយថវិកាជាមធ្យមប្រមាណ ១២១ប៊ីលានរៀល ជូនគ្រួសារប្រមាណ ៦៨ម៉ឺនគ្រួសារ ដែលគ្របដណ្តប់លើប្រជាជនប្រមាណ ២លាន ៧សែននាក់ ជារៀងរាល់ខែ។

**រូបភាពទី២៧** តាវកាលិក, ចំនួនគ្រួសារ, និងអត្តគាហក (ចុងគ្រានីមួយៗ)




## ៣.៣.២. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ[៤]

វិបត្តិនៃជំងឺកូវីដ-១៩ បានអូសបន្លាយដល់ចុងឆ្នាំ២០២២, ដែលនៅអំឡុងពេលនោះ ប្រទេសកម្ពុជាជាពិសេសប្រជាកសិករបានទទួលរងផលប៉ះពាល់ថ្មីបន្ថែមទៀត គឺគ្រោះទឹកជំនន់ និងការឡើងថ្លៃនៃទំនិញដែលបណ្តាលមកពីបញ្ហាសេដ្ឋកិច្ច-នយោបាយសកលជាពិសេស ពីជម្លោះរវាងប្រទេសអ៊ុយក្រែន និងប្រទេសរុស្ស៊ី។ ដោយពិនិត្យឃើញពីបញ្ហាប្រឈមរបស់ប្រជាជន ជាពិសេសគ្រួសារដែលងាយរងហានិភ័យ (គ្រួសារដែលសមាជិកជាជនមានពិការភាព, មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងទៅ, កុមារអាយុពី០-៥ឆ្នាំ) និងកំពុងរស់នៅក្បែរបន្ទាត់ភាពក្រីក្រ, រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ចំនួន ២បន្ថែមទៀត គឺកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ និង កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា។ យន្តការនៃការកំណត់អត្តសញ្ញាណ និងផ្ទេរប្រាក់ឧបត្ថម្ភ ធ្វើឡើងដូចគ្នានឹងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹង

៤ គ្រួសារងាយរងហានិភ័យសំដៅដល់គ្រួសារដែលមានជីវភាពលំបាក និងមានសមាជិកគ្រួសារមានភាពងាយរងគ្រោះ ១ក្នុងចំណោម ៥ដូចជា៖ ជនមានពិការភាព, កុមារអាយុក្រោម ២ឆ្នាំ, ជនចាស់ជរាមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ, ស្ត្រីជាមេគ្រួសារ និងរស់នៅដោយគ្មានស្វាមី, ឬគ្រួសារដែលមានសមាជិកសុទ្ធសឹងជាកុមារ និងមនុស្សចាស់ជរា (មិនមានសមាជិកគ្រួសារអាយុពី ១៩ -៥៩ឆ្នាំ) ដែលត្រូវបានកំណត់អត្តសញ្ញាណដោយក្រសួងផែនការ តាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

ជំងឺកូវីដ-១៩ ដោយក្រសួងផែនការជាអ្នកកំណត់អត្តសញ្ញាណ និងមូលនិធិជាតិជំនួយសង្គមជាអ្នកបើកប្រាក់ឧបត្ថម្ភ។

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ ត្រូវបានដាក់ឱ្យអនុវត្តសម្រាប់គ្រួសារងាយរងហានិភ័យ ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយគ្រោះទឹកជំនន់នៅតាមបណ្ដាខេត្តចំនួន ១៦ រួមមាន រាជធានីភ្នំពេញ, ខេត្តកណ្ដាល, តាកែវ, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប, កំពង់ធំ, កំពង់ចាម, ត្បូងឃ្មុំ, ក្រចេះ, កំពង់ឆ្នាំង, ព្រៃវែង, កំពត, ស្វាយរៀង, និងឧត្ដរមានជ័យ។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះផ្ដល់ជូនគ្រួសារចំនួន ៩៩ ១៦៩គ្រួសារ ដែលមានសមាជិកសរុប ៣៧២ ៨៥៩ នាក់ ដោយចំណាយថវិកាអស់ប្រមាណ ៤៦ ៧៩៩,១ លានរៀល (ប្រមាណ ១១,៤២ លានដុល្លារសហរដ្ឋអាមេរិក) ដោយគ្រួសារមួយទទួលបានប្រាក់ឧបត្ថម្ភចំនួន ១លើក។

ទន្ទឹមគ្នានេះដែរ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា ក៏បានដាក់ចេញឱ្យអនុវត្តនៅដើមខែធ្នូ ឆ្នាំ២០២២។ កម្មវិធីនេះ ផ្ដល់ប្រាក់ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យចំនួន ៣លើក លើកទី១ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២, លើកទី២ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣, និងលើកទី៣ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣។ រាជរដ្ឋាភិបាលបានចំណាយថវិកាសរុបចំនួនប្រមាណ ១៧៥ ៩៥១,១ លានរៀល សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ។ សម្រាប់ការបើកផ្ដល់លើកចុងក្រោយ មានគ្រួសារចំនួនប្រមាណ ៤៩៥ ៣០៧ គ្រួសារ ឬស្មើនឹងសមាជិកចំនួនប្រមាណ ១ ៨៣៣ ៣៤៤ នាក់ ទទួលបានអត្ថប្រយោជន៍ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ។

**តារាងទី២** កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា

| កាលបរិច្ឆេទ | តាវកាលិកបានផ្ទេរ (លានរៀល) | ចំនួនគ្រួសារទទួលបានតាវកាលិក | ចំនួនប្រជាជនទទួលបានតាវកាលិក |
|---|---|---|---|
| លើកទី១ (១០ ធ្នូ ២០២២) | ៣៦ ៤៦៣,៩ | ២៦០ ៥៣៥ | ៩៦៦ ៣១២ |
| លើកទី២ (១០ មេសា ២០២៣) | ៦៩ ៨៩៩,៩ | ៤៩៥ ៣០៧ | ១ ៨៣៣ ៣៤៤ |
| លើកទី៣ (១០ កក្កដា ២០២៣) | ៦៩ ៥៨៧,៣ | ៤៩៥ ៣០៧ | ១ ៨៣៣ ៣៤៤ |
| **សរុប** | **១៧៥ ៩៥១,១** | - | - |

## ៣.៣.៣. ការបណ្ដុះបណ្ដាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករនិយោជិត

ក្នុងអំឡុងពេលដែលប្រទេសកម្ពុជា ក៏ដូចជាពិភពលោកប្រឈមនឹងជំងឺកូវីដ-១៩ជាពិសេសក្នុងឆ្នាំ២០២១, រាជរដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធី និងអន្តរាគមន៍ឆ្លើយតបបន្ទាន់មួយចំនួនដើម្បីជួយកម្មករនិយោជិត ដែលក្នុងនោះ មានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិត ដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់ ដែលត្រូវបានអនុវត្តជា ៦ដំហាន និងបានជួយឧបត្ថម្ភដល់កម្មករនិយោជិតប្រមាណ ៣៤ម៉ឺននាក់ (៧៩,៥%ជាស្រ្តី)។ ជាមួយគ្នានេះ, កម្មវិធីបណ្ដុះបណ្ដាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ ក៏ត្រូវបានដាក់ឱ្យអនុវត្តផងដែរ ដែលបានចំណាយថវិកាជាមធ្យមប្រមាណ ២៤០ប៊ីលានរៀល ក្នុងមួយឆ្នាំ (ប្រមាណ ៥៨ លានដុល្លារសហរដ្ឋអាម៉េរិក) ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២។ កម្មវិធីនេះ បានបណ្ដុះបណ្ដាល និងជួយកម្មករនិយោជិតប្រមាណ ៣៧ម៉ឺននាក់ ក្នុងឆ្នាំ២០២០, ៧ម៉ឺន ៥សែននាក់ក្នុងឆ្នាំ២០២១, និង៩ម៉ឺន ៧សែននាក់ក្នុងឆ្នាំ២០២២ ដែលក្នុងនោះប្រមាណ ៨០% ជាស្រ្តី។

**តារាងទី៣** ចំនួនអត្ថគាហក នៃកម្មវិធីបណ្ដុះបណ្ដាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ និង កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិត ដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់ (នាក់)

| ល.រ | កម្មវិធី | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កម្មវិធីបណ្ដុះបណ្ដាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ | ៣៧០ ៧០៧ | ២៩៨ ១០០ | ៧៥ ០៦១ | ៥៥ ៦៨៩ | ៩៧ ៤២៨ | ៧៧ ០៦២ |
| ២ | ការឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិត ដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់ (ជំហានទី ១ ដល់ទី ៦) | | | ៣៤១ ៦៤២ | ២៧១ ៤៧៤ | | |

## ៣.៣.៤. ប្រព័ន្ធស្បៀងបម្រុង

ក្នុងយន្តការឆ្លើយតបនឹងគ្រោះអាសន្ន, ប្រព័ន្ធស្បៀងបម្រុងកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយឧបត្ថម្ភភ្លាមៗ និងជាប្រចាំដល់គ្រួសាររងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ដូចជាគ្រោះទឹកជំនន់, គ្រោះរាំងស្ងួត, ការផ្តល់ពូជដំណាំ ដើម្បីលើកកម្ពស់ជីវភាពគ្រួសារ និងប្រជាកសិករនៅក្នុងប្រទេសកម្ពុជា។ ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩, ប្រព័ន្ធស្បៀងបម្រុងកម្ពុជា ក៏បានដើរតួនាទីយ៉ាងសំខាន់ដោយបានផ្តល់ស្បៀងជូនគ្រួសារប្រមាណជា ៤០ម៉ឺនគ្រួសារ ក្នុងឆ្នាំ២០២១។ យ៉ាងណាមិញ, ចំនួនគ្រួសារដែលទទួលបានការឧបត្ថម្ភក្នុងប្រព័ន្ធស្បៀងបម្រុង មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យតាមគ្រោះមហន្តរាយ ដែលកើតមាន។

**តារាងទី៤** ចំនួនគ្រួសារ ដែលទទួលបានការឧបត្ថម្ភ ពីប្រព័ន្ធស្បៀងបម្រុង

| ល.រ | ប្រភេទគ្រោះមហន្តរាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ១ | គ្រោះទឹកជំនន់ | ៧៨ ៧៩៥ | ២៦ ០០៦ | ១៨០ ១១២ | ១៦ ៣៧៩ | ១៤៤ ៣៣៨ |
| ២ | ជំងឺកូវីដ-១៩ (ស្បៀង៖ អង្ករ មី ត្រីខ ទឹកត្រី ទឹកស៊ីអ៊ីវ និងទឹកបរិសុទ្ធ ) | - | - | - | ៣៩៩ ៦០០ | - |
| ៣ | ជំរុញការដាំដុះ (ការកែលម្អអាហារូបត្ថម្ភ បង្កើនប្រាក់សន្សំ និងប្រាក់ចំណូលក្នុងគ្រួសារ) | ៦១ ០៨២ | ៧៣ ១៧៤ | ១២៤ ១២០ | ៩៤ ៧២៥ | ៨៩ ៨៨៥ |
| សរុប | | ១៣៩ ៨៧៧ | ៩៩ ១៨០ | ៣០៤ ២៣២ | ៥១០ ៧០៤ | ២៣៤ ២២៣ |

# ៤.

## សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផល ៥ឆ្នាំកន្លងមកនេះ (២០១៨ ដល់ ២០២២) ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមមានភាពវិជ្ជមានជាច្រើន។ ការកើនឡើងនៃចំនួនអត្ថគាហក និងសហគ្រាសដែលបានចុះឈ្មោះបង់ភាគទាន ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត, ការគ្របដណ្តប់នៃមូលនិធិសមធម៌សុខាភិបាល ដែលស្តែងឡើងតាមរយៈចំនួនអត្ថគាហករួមមានប្រជាជនក្រីក្រ និងក្រុមប្រជាជនដ៏ទៃផ្សេងទៀត ក៏មានការកើនឡើងខ្លាំងផងដែរនាប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលការណ៍នេះបានបង្ហាញយ៉ាងច្បាស់ពីការពង្រីកវិសាលភាពនៃការគ្របដណ្តប់គួរឱ្យកត់សម្គាល់នៃប្រព័ន្ធសន្តិសុខសង្គម ក៏ដូចជាប្រព័ន្ធគាំពារសង្គមទាំងមូល ជាពិសេសលើការថែទាំសុខភាព។ ទន្ទឹមនឹងការកើនឡើងនៃចំនួនអត្ថគាហក, អត្រានៃការប្រើប្រាស់សេវាព្យាបាល និងថែទាំសុខភាពនៅតាមមូលដ្ឋានសុខាភិបាល ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដែលនេះជាសញ្ញាណមួយបង្ហាញពី ភាពប្រសើរឡើងនៃការយល់ដឹង និងទំនុកចិត្តរបស់ប្រជាជនលើការប្រើប្រាស់សេវាសុខាភិបាល។

ការឆ្លើយតបនឹងគ្រោះអាសន្ន ដែលស្តែងឡើងតាមរយៈកម្មវិធីផ្ទេរសាច់ប្រាក់អន្តរាគមន៍ភ្លាមៗជាពិសេសលើប្រជាជនក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ និងប្រជាជនងាយរងគ្រោះ ដែលរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់, និងសម្ពាធអតិផរណា, កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ, ការឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិត ដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់, និងប្រព័ន្ធស្បៀងបម្រុងកម្ពុជា បានចូលរួមដោយផ្ទាល់យ៉ាងសំខាន់ បញ្ចៀសបាននូវការធ្លាក់ចូលក្នុងភាពក្រីក្រធ្ងន់ធ្ងររបស់ប្រជាជន។ ក្នុងនោះកម្មវិធីផ្ទេរសាច់ប្រាក់ជូនប្រជាជនក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ បានអនុវត្ត ដែលបានគ្របដណ្តប់លើប្រជាជនក្រីក្រប្រមាណ ២លាន ៨សែននាក់ (១៦,៦% នៃចំនួនប្រជាជនសរុប) ត្រូវជាជាង ៧០ម៉ឺនគ្រួសារ។ រាជរដ្ឋាភិបាលត្រូវចំណាយថវិកាជាមធ្យមក្នុង១ខែ ប្រមាណ១២៦ប៊ីលានរៀល (៣០,៦លានដុល្លារសហរដ្ឋអាម៉េរិក) សម្រាប់ការអនុវត្តកម្មវិធីនេះ។

ជាការកត់សម្គាល់, ការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គមទាំងមូលមានការកើនឡើងជាបន្តបន្ទាប់ជាពិសេសចាប់ពីឆ្នាំ២០១៨មក ដែលចំណាយជារួមក្នុងប្រព័ន្ធគាំពារសង្គមបានកើនឡើងពី ១% នៃផ.ស.ស ក្នុងឆ្នាំ២០១៨ ដល់ជាង ៣% នៃផ.ស.ស ក្នុងឆ្នាំ២០២២ ដែលការណ៍នេះក៏បានឆ្លុះបញ្ចាំងពីឆន្ទៈ និងកិច្ចខិតខំរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹង និងពង្រីកប្រព័ន្ធគាំពារសង្គមកម្ពុជាឱ្យកាន់តែប្រសើរឡើង ប្រកបដោយបរិយាបន្ន។

## តារាងទី៩ តារាងសង្ខេបនៃចំនួនអត្ថគាហក កម្រិតនៃការគ្របដណ្តប់ អត្រានៃការប្រើប្រាស់ និងថវិកាបានផ្ទេរ ក្នុងរបប និងកម្មវិធីគាំពារសង្គមនីមួយៗ

| ល.រ | របប/កម្មវិធី | ចំនួនអត្ថគាហក | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០១៨ | ២០១៩ |
| ១ | មូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារក្រីក្រ | ២,៥៣០,០៦៩ | ២,៤៧៥,១៤៨ | ២,៩៨៦,២២១ | ៣,០១៦,៨១១ | ៣,១១២,១៤៨ | ១៥,៨ | ១៥,៣ |
| ២ | មូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមប្រជាជនដទៃ | ១២៤,៩៤៦ | ៨៨,១៩០ | ៩៣,៥៥៥ | ៩៤,៣៧៨ | ៩៦,១៩៨ | - | ០,៥ |
| ៣ | របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត | ១,២០២,៣៩៨ | ១,១៩៩,៤៦៣ | ១,២៦៣,៦៧៦ | ១,៣៨០,៤៥០ | ១,៤៣២,៥៥៥ | ១៤,៣ | ១៣,៩ |
| ៤ | របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ | ១,២០២,៣៩៨ | ១,២០៧,១៤១ | ១,០៩៦,២២៤ | ១,៣៨២,៣២៩ | ១,៤៣៤,៤០៧ | ១៤,៣ | ១៤,០ |
| ៥ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ | - | - | ២,៧០៧,២៥៣ | ២,៧០១,៥៣៨ | ២,៧៨៣,៨០៣[៩] | - | - |
| ៦ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ | - | - | - | - | ៣៧២,៨៥៩ | - | - |
| ៧ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យអំឡុងពេលមានសម្ពាធអតិផរណា | - | - | - | - | ៩៦៦,៣១២[១២] | - | - |

៥ ធៀបនឹងប្រជាជនសរុប
៦ ធៀបនឹងប្រជាជនសរុប
៧ ធៀបនឹងកម្លាំងពលកម្មសរុប
៨ ធៀបនឹងកម្លាំងពលកម្មសរុប
៩ តួលេខចុងគ្រា (ខែធ្នូ នៃឆ្នាំនីមួយៗ)
១០ ធៀបនឹងប្រជាជនសរុប
១១ ៦ ខែ
១២ គិតត្រឹមខែធ្នូ ឆ្នាំ២០២២
១៣ គិតត្រឹមខែធ្នូ ឆ្នាំ២០២២

| កម្រិតនៃការគ្របដណ្តប់ (%) | | | អត្រានៃការប្រើប្រាស់ (ដង/នាក់/ឆ្នាំ) | | | | | ថវិកាបានផ្ទេរ (លានរៀល) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២០ | ២០២១ | ២០២២ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១៨,២ | ១៨,២ | ១៨,៦[៥] | ១,១០ | ១,១៦ | ១,១០ | ១,០០ | ១,០០ | - | - | - | - | - |
| ០,៦ | ០,៦ | ០,៦[៦] | - | ០,៧៦ | ០,៨៥ | ០,៧៨ | ០,៨១ | - | - | - | - | - |
| ១៤,៥ | ១៥,៥ | ១៥,៩[៧] | ០,៩៩ | ២,០០ | ២,៣៤ | ១,៧២ | ១,៩៤ | ៦៨,១៦៦ | ១៣១,១៦៧ | ១៦៩,៣៩៥ | ១៣៦,៣២៦ | ១៣៥,៤០៨ |
| ១២,៦ | ១៥,៦ | ១៥,៩[៨] | - | - | - | - | - | ១០,៩៩០ | ៩,១៩០ | ៧,៩០១ | ៦,៧៨៧ | ៧,៨៤៧ |
| ១៦,៧ | ១៦,៥ | ១៦,៤[១០] | - | - | - | - | - | - | - | ១២២,០១៥[១១] | ១២១,៦៩៩ | ១២៥,៩៣៣ |
| - | - | - | - | - | - | - | - | - | - | - | - | ៤៦,៧៩៩,១ |
| - | - | - | - | - | - | - | - | - | - | - | - | ៣៦,៤៦៤[១៣] |

ក្រុមប្រឹក្សាជាតិគាំពារសង្គម

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

NATIONAL SOCIAL PROTECTION COUNCIL